ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៧៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០២០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា១៤៤ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១០ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច"គ" ផ្នែកទី៣ នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីសមាសភាពការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា សរសេរជាអក្សរកាត់ថា "**អ.ក.ជ.ប.អ.**" និងជាភាសាអង់គ្លេសថា **General Secretariat of National Council for Minimum Wage** សរសេរជាអក្សរកាត់ថា "**G.N.C.M.W.**"។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ អ.ក.ជ.ប.អ.

**មាត្រា២ .-**

**អ.ក.ជ.ប.អ.** មានតួនាទីជាសេនាធិការឱ្យ **ក.ជ.ប.អ.** សម្រាប់ប្រតិបត្តិការងារប្រចាំថ្ងៃ និងដឹកនាំសម្របសម្រួលការអនុវត្តការងារប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ។

**មាត្រា៣ .-**

**អ.ក.ជ.ប.អ.** មានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវនិងរៀបចំលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- សិក្សានិងរៀបចំគោលនយោបាយប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- សិក្សាលទ្ធភាពពង្រីកវិសាលភាពក្នុងការអនុវត្តប្រាក់ឈ្នួលអប្បបរមាលើវិស័យផ្សេងៗ ស្របតាមស្ថានភាពសេដ្ឋកិច្ចនិងសង្គម
- សិក្សា វិភាគ និងព្យាករណ៍អំពីការប្រែប្រួលនិងឥទ្ធិពលនៃប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- លើកកម្ពស់ការយល់ដឹងអំពីយន្តការនិងលក្ខណវិនិច្ឆ័យនៃការកំណត់ប្រាក់ឈ្នួលអប្បបរមា គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងលទ្ធផលស្រាវជ្រាវនានាពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- សម្របសម្រួលជាមួយភាគីពាក់ព័ន្ធដែលមានបំណងសិក្សាស្រាវជ្រាវនិងបណ្តុះបណ្តាលទាក់ទងនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- តាមដានការអនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមានិងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ

- រៀបចំកិច្ចប្រជុំពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗក្នុងក្របខ័ណ្ឌយន្តការត្រីភាគី
- រៀបចំផែនការ និងធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **ក.ជ.ប.អ.** និង **អ.ក.ជ.ប.អ.**
- ទទួលបន្ទុករៀបចំ គ្រប់គ្រង និងចាត់ចែងថវិកាប្រចាំឆ្នាំរបស់ **ក.ជ.ប.អ.** និង **អ.ក.ជ.ប.អ.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **ក.ជ.ប.អ.**។

**មាត្រា៤ .-**

**អ.ក.ជ.ប.អ.** ត្រូវដឹកនាំដោយអគ្គលេខាធិការ ១(មួយ)រូបដែលមានឋានៈស្មើអគ្គនាយក និងអគ្គលេខាធិការរងមួយចំនួនដែលមានឋានៈស្មើអគ្គនាយករង ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ .-**

**អ.ក.ជ.ប.អ.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែកគាំទ្រទូទៅនិងហិរញ្ញវត្ថុ
- ផ្នែកសិក្សាស្រាវជ្រាវ
- ផ្នែកផែនការនិងសហប្រតិបត្តិការ។

ផ្នែកនីមួយៗ ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអនុប្រធានមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់ **អ.ក.ជ.ប.អ.** ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

មន្ត្រីនៃ **អ.ក.ជ.ប.អ.** គឺជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងករណីចាំបាច់ **អ.ក.ជ.ប.អ.** អាចមានអ្នកជំនាញការ ទីប្រឹក្សា និងមន្ត្រីជាប់កិច្ចសន្យាបន្ថែមដើម្បីជួយបំពេញការងាររបស់ខ្លួន។

## ជំពូកទី៣

## តួនាទីនិងភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា៧ .-**

ផ្នែកគាំទ្រទូទៅនិងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងនិងចាត់ចែងកិច្ចការរដ្ឋបាលរបស់ **ក.ជ.ប.អ.** និង **អ.ក.ជ.ប.អ.**
- គ្រប់គ្រងនិងចាត់ចែងកិច្ចការហិរញ្ញវត្ថុរបស់ **ក.ជ.ប.អ.** និង **អ.ក.ជ.ប.អ.**
- គ្រប់គ្រង វាយតម្លៃ និងអភិវឌ្ឍសមត្ថភាពមន្ត្រីរបស់ **អ.ក.ជ.ប.អ.**
- គ្រប់គ្រងសម្ភារៈ បរិក្ខារផ្សេងៗ និងធ្វើបញ្ជីសារពើភណ្ឌរបស់ **អ.ក.ជ.ប.អ.**
- ធ្វើផែនការ និងរៀបចំសម្របសម្រួលរាល់កិច្ចប្រជុំនិងជំនួបពិភាក្សារបស់ **ក.ជ.ប.អ.** និង **អ.ក.ជ.ប.អ.**

- ធ្វើរបាយការណ៍ និងកំណត់ហេតុរាល់កិច្ចប្រជុំនិងជំនួបពិភាក្សារបស់ **ក.ជ.ប.អ.** និង **អ.ក.ជ.ប.អ.**
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គលេខាធិការនៃ **អ.ក.ជ.ប.អ.**។

**មាត្រា៨ .-**

ផ្នែកសិក្សាស្រាវជ្រាវមានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំផែនការសកម្មភាពក្នុងការសិក្សា និងស្រាវជ្រាវស្តីពីប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- សិក្សានិងរៀបចំគោលនយោបាយប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- ប្រមូល អង្កេត ចងក្រង និងសិក្សារាល់ទិន្នន័យ ឯកសារ និងព័ត៌មាននានា ដែលបម្រើឱ្យការសិក្សាស្រាវជ្រាវអំពីប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- សិក្សាលទ្ធភាពពង្រីកវិសាលភាពក្នុងការអនុវត្តប្រាក់ឈ្នួលអប្បបរមា ទៅតាមសកម្មភាពសេដ្ឋកិច្ចវិជ្ជាជីវៈ មុខរបរ ឬតំបន់ ដោយយោងទៅលើស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ប្រទេស
- សិក្សា ស្រាវជ្រាវ និងវិភាគលើលក្ខណវិនិច្ឆ័យតាមបែបសេដ្ឋកិច្ច និងសង្គម
- សិក្សា វិភាគ និងព្យាករណ៍អំពីការប្រែប្រួល និងឥទ្ធិពលនៃប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- សម្របសម្រួលជាមួយភាគីពាក់ព័ន្ធដែលមានបំណងសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលទាក់ទងនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- អភិវឌ្ឍ គ្រប់គ្រង និងថែរក្សាប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមបច្ចេកវិទ្យាព័ត៌មាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គលេខាធិការនៃ **អ.ក.ជ.ប.អ.**។

**មាត្រា៩ .-**

ផ្នែកផែនការនិងសហប្រតិបត្តិការមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ប្រមូលនិងចងក្រងផែនការសកម្មភាព និងសូចនាករពីគ្រប់ផ្នែក ដើម្បីរៀបចំផែនការសកម្មភាព និងសូចនាកររបស់ **ក.ជ.ប.អ.** និង **អ.ក.ជ.ប.អ.**
- ធ្វើផែនការសកម្មភាពការងាររយៈពេលខ្លី មធ្យម និងវែងរបស់ **អ.ក.ជ.ប.អ.**
- បូកសរុបនិងវាយតម្លៃទាំងបរិមាណ និងគុណភាពការងារតាមសូចនាករនៃផែនការសកម្មភាពដែលសម្រេចបាន
- ណែនាំរបៀបរបបនិងធ្វើរបាយការណ៍សរុបអំពីសកម្មភាព និងលទ្ធផលការងាររបស់ **ក.ជ.ប.អ.** និង **អ.ក.ជ.ប.អ.**
- បង្កើត ធ្វើបច្ចុប្បន្នកម្ម និងតាមដានគេហទំព័រនិងបណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ **ក.ជ.ប.អ.**
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ

- សហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងកៀរគរប្រភពធនធានទាំងក្នុងនិងក្រៅប្រទេស
- រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីជាមួយអង្គការ ស្ថាប័នជាតិ និងអន្តរជាតិនានា
- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងសេចក្តីណែនាំនានាដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញ និងលើកកម្ពស់ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- ប្រមូលនិងចងក្រងរាល់ឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- រៀបចំផលិតនិងផ្សព្វផ្សាយសៀវភៅ ផ្ទាំងរូបភាព សំឡេង វីដេអូ និងខិត្តប័ណ្ណព័ត៌មាននានាពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- លើកកម្ពស់ការយល់ដឹងអំពីយន្តការនិងលក្ខណវិនិច្ឆ័យនៃការកំណត់ប្រាក់ឈ្នួលអប្បបរមា គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងលទ្ធផលស្រាវជ្រាវនានាពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គលេខាធិការនៃ **អ.ក.ជ.ប.អ.**។

**មាត្រា១០ .-**

ផ្នែកនីមួយៗអាចមានការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យជំនាញតាមផ្នែកនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៤

## ប្រភពធនធានរបស់ អ.ក.ជ.ប.អ.

**មាត្រា១១ .-**

ការចំណាយសម្រាប់ដំណើរការរបស់ **អ.ក.ជ.ប.អ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**អ.ក.ជ.ប.អ.** មានសិទ្ធិទទួលចាត់ចែងនិងប្រើប្រាស់នូវមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន ស្របតាមនីតិវិធីដូចបានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១ រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២០**

**ស្ដីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា**

**អង្គការលេខ នៃ អ.ក.ជ.ប.អ.**




**សម្គាល់**

- ទំនាក់ទំនងប្រយោល ------------
- ទំនាក់ទំនងផ្ទាល់ ⟶